ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ០០៩១ សរាចរ កសក

# សេចក្តីណែនាំ

# ស្តីពី

# វិធានការទប់ស្កាត់ការរាតត្បាតជំងឺជ្រុះស្លឹក Pestalotiopsis និងព្យាបាលជំងឺនេះ ដល់គ្រប់បណ្តាចម្ការកៅស៊ូ នៅទូទាំងប្រទេស

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជម្រាបដល់គ្រប់ប្រតិបត្តិករកៅស៊ូទាំងអស់ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងអ្នកដាំដុះឱ្យបានជ្រាបថា ថ្មីៗនេះមានករណីផ្ទុះជំងឺជ្រុះស្លឹក Pestalotiopsis នៅតំបន់ចម្ការកៅស៊ូ ក្នុងក្រុមហ៊ុន កោះកុង រ៉ាប់ប៊ើរ ផ្លេនថេសិន ដែលមានមូលដ្ឋានស្ថិតនៅឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង។ ជំងឺជ្រុះស្លឹក Pestalotiopsis ដែលបង្កឡើងដោយផ្សិតឈ្មោះ Pestalotiopsis sp. គឺជាប្រភេទជំងឺដ៏កាចសាហាវ និងរាតត្បាតលឿនបំផុតនៅលើចម្ការកៅស៊ូមានស្លឹកចាស់ៗ ជាពិសេសចម្ការកៅស៊ូកំពុងប្រមូលផល ដែលបណ្តាលឱ្យដំណាំកៅស៊ូជ្រុះស្លឹកអស់ពី៧០-៩០% និងបាត់បង់ទិន្នផលប្រមាណពី២៥-៥០%។ នៅក្នុងឆ្នាំ២០១៦ សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) បានប្រកាសអាសន្នអំពីប្រភពនៃការរាតត្បាតជំងឺនេះ នៅកោះស៊ូម៉ាត្រា ប្រទេសឥណ្ឌូនេស៊ី ហើយរហូតមកដល់បច្ចុប្បន្ន ជំងឺនេះបានរីករាលដាលជាបន្តបន្ទាប់ដល់ប្រទេសដាំកៅស៊ូចំនួន៥ទៀតគឺៈ ប្រទេសម៉ាឡេស៊ី ថៃ ឥណ្ឌា ស្រីលង្កា និងវៀតណាមភាគខាងជើង។

ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺជ្រុះស្លឹក Pestalotiopsis ពីតំបន់ចម្ការកៅស៊ូមួយទៅតំបន់ចម្ការកៅស៊ូមួយនៅទូទាំងប្រទេសឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមធ្វើការណែនាំដល់គ្រប់ប្រតិបត្តិករកៅស៊ូទាំងអស់ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងអ្នកដាំដុះត្រូវចូលរួមសហការ និងចាត់វិធានការទប់ស្កាត់ដូចខាងក្រោម៖

១.ផ្អាកជាបណ្តោះអាសន្នរាល់ការធ្វើចរាចររុក្ខសម្ភារកៅស៊ូ ចេញពីតំបន់ដែលកំពុងរងការរាតត្បាតពីជំងឺជ្រុះស្លឹក Pestalotiopsis (ខេត្តកោះកុង) ទៅកាន់តំបន់ផ្សេងៗទៀត។

២.ពង្រឹងការត្រួតពិនិត្យ និងអនុវត្តនូវវិធានការភូតគាមអនាម័យឱ្យបានត្រឹមត្រូវ ចំពោះការនាំចូល និងចរាចររុក្ខសម្ភារកៅស៊ូពីបណ្តាប្រទេសជិតខាង សម្រាប់បម្រើការដាំដុះនៅទូទាំងប្រទេស និងត្រូវបង្កើតច្បារពូជថ្នាលបណ្តុះកូនកៅស៊ូ ឬទិញរុក្ខសម្ភារកៅស៊ូដែលផលិតនៅក្នុងស្រុក។

៣.រាយការណ៍ជាបន្ទាន់មកអគ្គនាយកដ្ឋានកៅស៊ូ ដើម្បីមានវិធានការទប់ស្កាត់បានទាន់ពេលវេលា ក្នុងករណីសង្កេតឃើញថាចម្ការកៅស៊ូមានការរាតត្បាតជំងឺ ឬជ្រុះស្លឹកមិនប្រក្រតី។

៤.ក្នុងករណីរកឃើញថាមានកើតជំងឺជ្រុះស្លឹក Pestalotiopsis នៅលើចម្ការកៅស៊ូ ម្ចាស់ចម្ការត្រូវអនុវត្តវិធីសាស្ត្រព្យាបាលដូចខាងក្រោម៖

- ត្រូវប្រើថ្នាំសម្លាប់ផ្សិតប្រភេទឌីតានM45 (បរិមាណ១គ.ក្រលាយទឹក១០០លីត្របាញ់ ៤ដង/ខែ)
- ត្រូវដាក់ជីបំប៉ន (NPK ១៥-១៥-១៥ ចំនួន៣ដង/ឆ្នាំ ចាប់ពីខែឧសភាដល់ខែតុលា)

Scanned with CamScanner

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

- ត្រូវប្រមូលស្លឹកដែលជ្រុះដុតចោល និងសម្អាតតាមចន្លោះរងកៅស៊ូឱ្យបានស្អាត
- ត្រូវហាមឃាត់អ្នកពាក់ព័ន្ធក្នុងចម្ការកៅស៊ូ និងប្រជាពលរដ្ឋជុំវិញកុំឱ្យចេញ-ចូលក្នុងតំបន់រាតត្បាតជំងឺដែលអាចជាប្រភពចម្លងទៅតំបន់ដទៃៗទៀត។

ទទួលបានសេចក្តីណែនាំនេះ សូម ប្រតិបត្តិករកៅស៊ូទាំងអស់ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងអ្នកជាប់ពាក់ព័ន្ធទាំងប្រទេស ត្រូវចូលរួមសហការអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ៨កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០២២
**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

Scanned with CamScanner